# ឧបស្សយានិសង្ស

"អានិសង្សនៃសាលាសំណាក់"

ក្នុងព្រះសុត្តន្តបិដក សំយុត្តនិកាយ ទេវតាសំយុត្ត សគាថវគ្គ ត្រង់សត្តមសូត្រ ក្នុងអាទិត្តវគ្គ មានសេចក្ដីថ្លែងថា មានទេវតាក្រាបទូលសួរព្រះភគវ័ត អរហន្តសម្មាសម្ពុទ្ធថា:

**កេសំ ទិវា ច រត្តោ ច    សទា បុញ្ញំ បវឌ្ឍតិ**
**ធម្មដ្ឋា សីលសម្បន្នា    កេ ជនា សគ្គគាមិនោ ។**

"(សូមទ្រង់ព្រះមេត្តាប្រោស)" បុណ្យរមែងចម្រើនជានិច្ចទាំងថ្ងៃទាំងយប់ ដល់ជនទាំងឡាយណាខ្លះ ជនទាំងឡាយណាខ្លះជាអ្នកឋិតនៅក្នុងធម៌ ជាអ្នកបរិបូណ៌ដោយសីល ហើយគេបានទៅកើតឯឋានសួគ៌ ?

ព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់ឆ្លើយដោះស្រាយបញ្ហានេះថា:

**អារាមរោបា វនរោបា    យេ ជនា សេតុការកា**
**បបញ្ច ឧទបានញ្ច    យេ ទទន្តិ ឧបស្សយំ**
**តេសំ ទិវា ច រត្តោ ច    សទា បុញ្ញំ បវឌ្ឍតិ**
**ធម្មដ្ឋា សីលសម្បន្នា    តេ ជនា សគ្គគាមិនោ ។**

ជនទាំងឡាយណា បានដាំសួនមានផ្កាមានផ្លែក្ដី បានដាំឈើជាឧទ្យានមានម្លប់ត្រឈឹងត្រឈៃក្ដី បានសង់ស្ពានក្ដី បានដងទឹកដាក់តម្កល់ទុកឱ្យទានក្ដី បានជីកអណ្ដូងឬជីកស្រះក្ដី បានសាងសង់ឧបស្សយដ្ឋាន

គឺសាលាសំណាក់ជាដើមក្តី បុណ្យរមែងចម្រើនកើតកើនជានិច្ចទាំងថ្ងៃទាំងយប់ដល់ជនទាំងឡាយនោះ ។ ជនទាំងឡាយណា ជាអ្នកឋិតនៅក្នុងកុសលធម៌ ជាអ្នកបរិបូណ៌ដោយសីល, ជនទាំងឡាយនោះ ជាអ្នកបានទៅកើតឋានសួគ៌ ។

## អធិប្បាយ

តាមលំអាននៃគម្ពីរសារត្ថប្បកាសនី អដ្ឋកថាសំយុត្តនិកាយ សគាថ-វគ្គ ត្រង់ទេវតាសំយុត្តវណ្ណនា ព្រមទាំងការពង្រីកសេចក្តីឱ្យទូលំទូលាយខ្លះផង តាមមតិនៃខ្ញុំជាអ្នករៀបរៀងធម៌នេះ ។

ត្រង់ដែលទេវតាក្រាបទូលសួរព្រះភគវ័ត ព្រះអរហន្តសម្មាសម្ពុទ្ធថា: **កេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ** "បុណ្យរមែងចម្រើនជានិច្ចទាំងថ្ងៃទាំងយប់ ដល់ជនទាំងឡាយណាខ្លះ ? នោះព្រះភគវ័តទ្រង់ឆ្លើយដោះស្រាយថា **អារាមរោបា** អ្នកណាបានដាំបុប្ផារាមនិងផលារាម គឺបានដាំឈើដែលមានផ្កា ដូចជាម្លិះ, ន្ទូនស្រី, មាលតី, ដកខិម, ចំប៉ីជាដើម ឬបានដាំឈើមានផ្លែ ដូចជាត្របែក, ពុទ្រា, ត្រប់, ម្ទេសជាដើម ដែលជាឈើតូចៗ ទាប ៗ ក្នុងវត្តអារាមជាទីនៅនៃភិក្ខុសង្ឃ ឬដាំនៅទីណាមួយ ឱ្យជាសាធារណប្រយោជន៍ដល់ជនទាំងពួង, យ៉ាងនេះហៅថា **អារាមរោបា** អ្នកដាំសួនមានផ្កាមានផ្លែ ។ **វនរោបា** បានធ្វើរបងព័ទ្ធទីដី ដែលមានឈើជាព្រៃដុះឯង

ស្រាប់ ឥតមានអ្នកណាមួយដាំទេ ជាទីដីទំនេរឥតមានអ្នកណាមួយហួង-ហែងថែរក្សាទេ ឬជាទីដីរបស់ខ្លួន បានសាងចេតិយ, បានដាំដើមពោធិ៍ , បានធ្វើផ្លូវជាទីចង្ក្រមន៍ ឬបានសង់មណ្ឌប, សង់សាលា, តូប, អាស្រម, លេណដ្ឋាន សម្រាប់នៅជ្រកអាស្រ័យនៃយោគី, តាបស អាចប្រើប្រាស់បានក្នុងវេលាថ្ងៃ ឬយប់តាមត្រូវការ, យ៉ាងនេះហៅថា **វនរោបា** អ្នកដាំឈើឧទ្យានមានម្លប់ត្រឈឹងត្រឈៃ ។ ពុំនោះសោត បានដាំឈើជាម្លប់ឱ្យគេជ្រក ទោះដាំនៅទីជិតសាលាសំណាក់ក្តី នៅទីក្បែរថ្នល់ ក្បែរផ្លូវក្តី នៅទីដីក្នុងវត្តអារាមក្តី ដាំធ្វើជាឧទ្យានមានម្លប់ត្រឈឹងត្រឈៃក្តី ឱ្យជាម្លប់ជាជម្រកជាទីពេញចិត្តខ្លួនឯងនិងសាធារណ-ជនទាំងពួង, យ៉ាងនេះក៏ហៅថា **វនរោបា** អ្នកដាំឧទ្យានមានម្លប់ត្រឈឹងត្រឈៃដែរ ។

**សេតុការកា** **ជនា** **យេ** ជនទាំងឡាយណា បានសង់ស្ពាន, **ឧទកេ នាវំ បដិយាទេន្តិ** ឬបានចាត់ចែងឱ្យមានទូកសម្រាប់ចម្លងដោយឥតយកថ្លៃឈ្នួល ឱ្យសាធារណជនបានឆ្លងទឹកដោយងាយស្រួល, អ្នកដែលមានចិត្តជាកុសល បានលើកថ្នល់ ឬជម្រះស្មៅ ចូកចាំងពង្រាបផ្លូវឬក៏បានលុបថ្លុកជង្ហុកធ្វើជាផ្លូវជាថ្នល់ឱ្យមានផ្ទៃរាបស្មើ ស្រួលដើរ ស្រួលធ្វើគមនាគមន៍ ទោះថ្ងៃទោះយប់មិនចំពប់ មិនរអិល ឬពុំនោះ កាលបើបានឃើញមានមែកឈើឬបន្ទាជាដើម រាត់រាយនៅក្នុងផ្លូវ មិនដើរបង្ហួស

ទៅ ក៏បានទាត់ចោល ឬបានចាប់រើសបោះចោលដោយស្រួលទៅក្រៅផ្លូវ, មានចបនៅនឹងដៃ កាលបើបានឃើញផ្លូវឬថ្នល់រិកលខូចខាត ក៏ឆ្លៀតលើកដីបំពេញដោយចិត្តជ្រះថ្លា, យ៉ាងនេះក៏សុទ្ធសឹងតែជាបុណ្យជាកុសលមានផលល្អប្រពៃទាំងអស់ ។

**បបញ្ហា ឧទបានញ្ហា** ជាអ្នកមានចិត្តជាកុសល បានធ្វើពាងតូចដាក់ក្អមឬពាងទឹក ព្រមទាំងផ្តិលឬបោយត្រឡោកសម្រាប់ដួសដងផង ឱ្យជាទានដល់សាធារណជន នៅទីប្រសព្វផ្លូវតូចធំ ក្នុងរដូវដែលក្រទឹក ។ បានជីកស្រះ ជីកត្រពាំង ជីកអណ្តូង ឬលើកទំនប់បង្ហាំងទឹកឱ្យដក់នៅជានិច្ចកាល ជាប្រយោជន៍ដល់មនុស្សនិងសត្វតិរច្ឆានទូទៅ ។ ពុំនោះសោត បានធ្វើប៉ប៉ា[១] គឺឃ្លាំងសម្រាប់ទទួលទឹកភ្លៀងដែលហូរធ្លាក់ចុះចាកដំបូលសាលាធំៗ ជាដើម ទុកជាប្រយោជន៍ដល់ភិក្ខុសាមណេរនិងសាធារណជនដួសដងយោងយកមកប្រើប្រាស់បានដោយងាយ, ការទាំងនេះក៏សុទ្ធសឹងតែជាបុណ្យកុសល អាចនឹងផ្តល់នូវសេចក្តីសុខចម្រើនឱ្យដល់អ្នកកសាងនោះវិញ ពុំមែនតូចតាចស្តួចស្តើងឡើយ ។

**យេ ទទន្តិ ឧបស្សយំ**[២] ជនទាំងឡាយណា បានសាងសង់នូវ ***ឧបស្ស័យ ឬ វាសាគារ***គឺសាលាសម្រាប់ជ្រក សម្រាប់សំណាក់

---

១- អានថា ប៉ះប៉ា ។ ២- បាលីនេះប្រើជា ឧបាសយំ វិញក៏បាន មានន័យត្រូវគ្នានឹងឧបស្សយំ នេះដែរ គឺវាសាគារ អាគារជាទីសំណាក់អាស្រ័យ ឬ ជាលំនៅ ។

នៃសាធារណជនទូទៅពុំរើសមុខ, ឬក៏បានសាងសង់កុដិ, តូប, ឧបដ្ឋានសាលា, មន្ទីរពេទ្យជាដើម ក្នុងវត្តអារាមរបស់ភិក្ខុសង្ឃ, ពុំនោះ បានសង់តូប, អាស្រម, សម្រាប់យោគី តាបស ឥសី នៅជ្រកអាស្រ័យធ្វើការនាជាដើម, រួមសេចក្ដីខ្លីថា បានសាងសង់បានឱ្យនូវឧបស្សយ ឬវាសាគារជាទាន នេះក៏ជាបុណ្យកុសលជាទីជ្រះថ្លាទាំងអស់ ។

**តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ** ជនទាំងឡាយណាបានកសាងសន្សំនូវបុណ្យកុសលខាងលើនេះ, កាលបើជនទាំងឡាយនោះ នឹកឃើញការកុសលរបស់ខ្លួននោះនៅវេលាណាទោះនៅវេលាដើរ ឈរ អង្គុយ ឬដេកក្ដី វេលានោះឯង បុណ្យក៏ចេះតែលូតលាស់ចម្រើនកើនឡើងជានិច្ចជាងពីមុនថែមទៅទៀត ទាំងថ្ងៃទាំងយប់ ព្រោះជនទាំងនោះមានអំណរជ្រះថ្លារីករាយពេញចិត្ត មានសង្ឃឹមកក់ក្ដៅរឿយៗ ក្នុងវេលាដែលខ្លួននឹកឃើញបុណ្យនោះឯង ។ ប៉ុន្តែ ផ្ទុយទៅវិញ, ក្នុងពេលខ្លះ, បើជនអ្នកកសាងកុសលនោះ មិនភ្នកនឹកដល់កុសលដែលខ្លួនបានកសាងសន្សំហើយនោះទេ បែរជាមានចិត្តវិបល្លាសភ្វាសនឹកទៅរក **អកុសលវិតក្កៈ** ណាមួយទៅវិញ គឺត្រិះរិះនឹកភាំងស្មុងទៅរក **កាមវិតក្កៈ** ត្រិះរិះទៅរកកាមគុណទាំង៥ ណាមួយក្ដី, **ព្យាបាទវិតក្កៈ** ត្រិះរិះទៅរកការព្យាបាទផ្ដន្ទាគេ ចង់គំនុំគុំកួនគេក្ដី, **វិហឹសាវិតក្កៈ** ត្រិះរិះទៅរកការបៀតបៀនគេក្ដី ឬនឹកទៅរកអកុសលកម្មណាមួយផ្សេងដែលខ្លួនបានជ្រុល

ធ្វើទៅហើយនោះក្តី, បុណ្យកុសលពុំមែនលូតលាស់ចម្រើនកើនឡើងជានិច្ចរាល់ថ្ងៃរាល់យប់ ដូចបានពោលហើយនោះទេ, បើជននោះធ្លាប់បានធ្វើបាបណា កាលបើនឹកឃើញបាបនោះ ក៏ស្រាប់តែមាន **វិប្បដិសារៈ** ក្តៅក្រហាយស្តាយក្រោយ ព្រោះបាបនោះ, យ៉ាងនេះ បែរទៅជាបាបនោះលូតលាស់ចម្រើនកើនថែមៗ ឡើងទៀតលើសជាងមុនទៅវិញ ។ ដោយហេតុនេះ បុគ្គលពុំគួរនឹកទៅរកបាបចាស់នោះទេ ត្រូវបំភ្លេចបាប ត្រូវតាំងចិត្តឱ្យត្រេកអរទាំងត្រូវសង្ឃឹមយ៉ាងមាំផង ទៅរកបុណ្យដែលខ្លួនបានធ្វើរួចហើយនោះ ឬត្រូវផ្ចង់ចិត្តឱ្យមាំស៊ប់ផ្តោតចំពោះត្រង់បុណ្យដែលខ្លួនកំពុងធ្វើ ឱ្យចិត្តមានអំណររីករាយថែមៗឡើង ឬក៏ត្រូវផ្គង់ចិត្តឱ្យមុតមាំទៅរកការកុសល ដែលខ្លួនបម្រុងនឹងធ្វើរឿយៗតៗទៅទៀតនោះវិញ, យ៉ាងនេះ ហៅថានឹកបុណ្យនាំឱ្យបានបុណ្យថែមឡើងទៀត ឬហៅថា **នឹកបុណ្យបំភ្លេចបាប** ដូច្នេះវិញក៏សឹងតែថាបាន ។ ព្រះអរហន្តសម្មាសម្ពុទ្ធជាបរមគ្រូ ពុំដែលប្រទានព្រះឱវាទថា **ធ្វើបុណ្យលាងបាបទេ**, ព្រះពុទ្ធសាសនា **គ្មានពិធីលាងបាបឡើយ**, មានត្រឹមតែថា **សុខោ បុញ្ញស្ស ឧច្ចយោ** ការសន្សំបុណ្យនាំឱ្យបានសេចក្តីសុខ ។ **ទុក្ខោ បាបស្ស ឧច្ចយោ** ការសន្សំបាបនាំឱ្យបានសេចក្តីទុក្ខ ។ **តមោជោតិបរាយនោ** បុគ្គលចេញពីទីងងឹតមកកាន់ទីភ្លឺ ហៅថាងងឹតខាងដើមភ្លឺខាងចុង ។ បុគ្គលណា កាលពីមុន មានគំនិតងងឹតងងល់

លង់ស្មុងទៅខាងបាប លុះដល់មកខាងក្រោយភ្ញាក់គំនិតបានប្រព្រឹត្តត្រឹមត្រូវល្អតាមគន្លងធម៌ពិត, បុគ្គលនោះក៏ភ្លឺរុងរឿងដោយសារបុណ្យកុសល **អព្ភា មុត្តោវ ចន្ទិមា** ដូចជាព្រះចន្ទ្រចេញផុតពីពពកបាំង ។ គួរយល់ថា បុណ្យជាកុសលបំភ្លេចបាប, ឯបាបជាអកុសលបំភ្លេចបុណ្យ ឬបង្អាក់បង្អាប់បុណ្យ, ត្រេកអរចំពោះបុណ្យ បុណ្យឱ្យផលជាសុខ ឱ្យមានចិត្តរីករាយ, ត្រេកអរចំពោះបាប បាបឱ្យផលជាទុក្ខ ឱ្យមានសេចក្តីក្តៅក្រហាយស្តាយក្រោយ ។ នេះជាលទ្ធិនៃព្រះពុទ្ធសាសនា ចង្អុលប្រាប់ការណ៍ពិតឥតមានល្អៀងឡើយ ។ ដោយហេតុនេះហើយបានជាព្រះសព្វញ្ញុពុទ្ធវិសេសវិសុទ្ធបរមសាស្តា ទ្រង់ឆ្លើយតបបញ្ហាដែលទេវតាក្រាបទូលសួរនោះថា **វេតសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ** (ដែលបានប្រែព្រមទាំងបានអធិប្បាយផងរួចហើយនោះ) ។

**ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ** ជនទាំងឡាយណាឋិតនៅក្នុងកុសលធម៌ផង បរិបូណ៌ដោយសីលផង ជនទាំងឡាយនោះ តែងតែបានទៅកើតឯឋានសួគ៌ ។ ពាក្យថា **ឋិតនៅក្នុងកុសលធម៌** គឺប្រព្រឹត្តត្រឹមត្រូវតាមគន្លងធម៌មានសុចរិត ១០ ប្រការជាដើម ។ ពាក្យថា **បរិបូណ៌ដោយសីល** គឺកាន់សីលតាំងពីសីល ៥ ជាដើមទៅ ដោយប្រយ័ត្នជានិច្ចមិនឱ្យសៅហ្មង ។

ចប់សត្តមសូត្រទី៧ ក្នុងអាទិត្តវគ្គតែប៉ុណ្ណោះ

# មឃមាណវវត្ថុ

## "រឿងនិទានមឃមាណពទៅកើតជាព្រះឥន្ទ"

ក្នុងគម្ពីរធម្មបទដ្ឋកថា ត្រង់អប្បមាទវគ្គវណ្ណនា មានតំណាលអំពីរឿងមឃមាណព[១] និងមិត្រ ៣៣ នាក់ ដែលបានរួបរួមគ្នាបំពេញការកុសល ក្នុងពុទ្ធន្តរកាល គឺក្នុងកាលលង្វែកឥតមានព្រះពុទ្ធសាសនា ។ មឃមាណពនិងមិត្រ៣៣នាក់នោះ មានចិត្តជ្រះថ្លា បានសាងសន្សំកុសលមានការជម្រះស្មៅចូកចាំងប្រាបពង្រាបផ្លូវ លើកថ្នល់ សង់ស្ពាន សង់សាលាសំណាក់ជាដើម ជាប្រយោជន៍ដល់សាធារណជន, លុះអស់ជីវិតបានទៅកើតជាព្រះឥន្ទ ជាទេវបុត្ត ជាទេវតាទាំងអស់គ្នា នៅឋានត្រ័យត្រិង្សសួគ៌ ។ និទាននោះ មានសេចក្ដីពិស្ដារ ប៉ុន្តែ, ដើម្បីកុំឱ្យសៀវភៅនេះក្រាស់ពេក, ខ្ញុំដកស្រង់ត្រឹមតែគោលខ្លីៗ យកមករៀបរៀង ដូចតទៅនេះ ៖

ព្រះសក្យមុនីសម្មាសម្ពុទ្ធ ទ្រង់គង់នៅនា កូដាគារសាលា មហាវ័នជិតក្រុងវេសាលីដែនវជ្ជី ។ ព្រះរាជាទ្រង់ព្រះនាម មហាលិ ក្នុងពួកលិច្ឆវីក្សត្រិយ៍ នៃក្រុងវេសាលី ដែនវជ្ជីក្នុងជម្ពូទ្វីប, ដោយព្រះអង្គបានទ្រង់ព្រះសណ្ដាប់នូវ សក្កបញ្ហសូត្រ ដែលព្រះបរមសាស្ដាទ្រង់សំដែង

---

១- ពុទ្ធសាសនិកជនខ្មែរយើងច្រើនតែហៅថា មាឃមាណព ប៉ុន្តែ តាមពិត មឃមាណពវិញទេ ទើបត្រឹមត្រូវ ដល់បានទៅកើតជាព្រះឥន្ទ ៗ ក៏មានព្រះនាមពិសេសមួយថា មឃទេវរាជដែរ ពុំមែន មាឃទេវរាជទេ ។

អំពីរឿងព្រះឥន្ទ, ព្រះមហាលិភជមានសេចក្ដីឆ្ងល់ថា មានព្រះឥន្ទពិតមែន, ព្រះភគវ័តទ្រង់បានទតព្រះនេត្រឃើញព្រះឥន្ទពិតមែន ឬព្រះអង្គទ្រង់សំដែងតាមរឿងព្រេងដែលគេធ្លាក់ គេគូរជារូបព្រះឥន្ទថា ព្រះឥន្ទៗ នោះទៅទេ ? ឬយ៉ាងណាអ៊ីចេះ ? ពីព្រោះឥតអ្នកណាអាចបានឃើញ បានស្គាល់ព្រះឥន្ទនោះដោយងាយៗ ទេ!

លុះព្រះបាទមហាលិ បានចូលមកគាល់ទូលសួរព្រះអង្គអំពីរឿងនេះ, ព្រះបរមគ្រូក៏បានឆ្លើយដោះស្រាយតាមការណ៍ពិតថា មានព្រះឥន្ទពិតមែន តថាគតបានឃើញ បានស្គាល់ព្រះឥន្ទនោះពិតៗ តថាគតស្គាល់ទាំងធម៌និងវត្តប្រតិបត្តិដែលធ្វើឱ្យអ្នកប្រតិបត្តិបានផលានិសង្សនាំអ្នកនោះទៅកើតជាព្រះឥន្ទផងទៀត, ពុំមែនតថាគតចេះតែថាៗ ទៅដោយពុំឃើញពុំស្គាល់ច្បាស់នោះទេ ។ ទើបព្រះបរមគ្រូទ្រង់សំដែងរឿងពិតនោះថា ៖

**អតីតេ មគធរដ្ឋេ អចលគាមេ មឃោ នាម មាណវោ** ក្នុងអតីតកាលកន្លងរំលងទៅយូរហើយ មានមាណពម្នាក់ឈ្មោះ**មឃះ** នៅក្នុងអចលគ្រាមក្នុងមគធរដ្ឋ, មឃមាណពនោះបានធ្វើបុណ្យកុសល រួមជាមួយនឹងបុរស៣៣នាក់ជាមិត្ររបស់ខ្លួន, បានរួបរួមគ្នាធ្វើការកុសលផ្សេងៗ មានការជម្រះស្មៅ ចូកចាំងប្រាបពង្រាបសំអាតផ្លូវ លើកថ្នល់ សង់ស្ពាន សង់សាលាសំណាក់ជាដើម ជាប្រយោជន៍

ដល់សាធារណជន ។ មឃមាណពនោះ ពុំមែនត្រឹមតែមានសទ្ធាជ្រះ-ថ្លាធ្វើការកុសលទាំងនេះប៉ុណ្ណោះទេ ថែមទាំងបានប្រព្រឹត្តកាន់ធម៌ជាកុសលឯទៀតដែលទេវតានិងមនុស្ស ជាបណ្ឌិតទាំងឡាយពេញចិត្តស្ញើចសរសើរនោះផងទៀត ។ ធម៌ដែលមឃមាណពកាន់ខ្ជាប់ជានិច្ចនោះហៅថា **វត្តបទ** មាន៧ប្រការគឺ ៖

១- ***មាតាបេតិភរណៈ*** *ការចិញ្ចឹមបីបាច់រក្សាមាតាបិតា;*

២- ***កុលេជេដ្ឋាបចាយនៈ*** *ការគោរពកោតក្រែងចាស់ព្រឹទ្ធាចារ្យត្រកូលរៀមច្បង;*

៣- ***សច្ចវាចា*** *ការពោលពាក្យសច្ចៈ,*

៤- ***អផរុសវាចា*** *ការមិនពោលផរុសវាទ,*

៥- ***បិសុណវាចា*** *ការមិនពោលពាក្យញុះញង់,*

៦- ***មច្ឆេរវិនយៈ*** *ការនាំសេចក្ដីកំណាញ់ចេញ គឺការបណ្ដុះសទ្ធាជ្រះថ្លាចំណាយទ្រព្យធ្វើបុណ្យឱ្យទាន,*

៧- ***អក្កោធនៈ*** *ការបេះអត់បេះទប់សេចក្ដីក្រោធ។*

*កាលដែលមឃមាណពនិងមិត្រទាំង ៣៣ នាក់ កំពុងធ្វើការកុសលមានការប្រាប់ពង្រាបផ្លូវនិងការលើកថ្នល់ ពីទីមួយភ្ជាប់គ្នាទៅទីមួយដូច្នោះ,*

គាមភោជក(១) បានរករឿងចាប់ទោសកំហុសថាជនទាំងនោះជាចោរប្រ-មូលផ្តុំគ្នាជាពួក, ក៏បានក្រាបទូលព្រះរាជា មគធរដ្ឋ ដោយអាងលេសផ្សេងៗ ជាអយុត្តិធម៌ ។ ព្រះរាជាពុំបានពិចារណាដោយហ្មត់ចត់ ព្រះអង្គជឿសំដីគាមភោជក, ក៏មានព្រះរាជបញ្ជាឱ្យចាប់ជនទាំង ៣៤ នាក់នោះមក ហើយឱ្យយកដំរីសឹកទៅបំព្រេចសម្លាប់ ។ មឃមាណពនិងមិត្រទាំង ៣៣ នាក់ បានតាំងចិត្តប្រកបដោយមេត្តាធម៌ដ៏មុតមាំ ឥតតក់ស្លុតរន្ធត់ ព្រោះជឿស៊ប់ចំពោះសុចរិតធម៌ ព្រមទាំងកុសលកម្ម ដែលបានកសាងសន្សំមកហើយនោះផង ជឿទុកចិត្តលើមេត្តាធម៌ ដែលខ្លួនកំពុងកាន់នោះផង គឺរំលឹកគ្នាមិនឱ្យខឹងប្រកាន់ទៅលើគាមភោជក, ទៅលើព្រះរាជា, ទៅលើដំរីសឹក និងជនឯទៀតៗ សូម្បីបន្តិចបន្តួចសោះឡើយ ។ ទោះបីគេឱ្យជនទាំង ៣៤ នាក់នោះនៅក្នុងរបាំងកន្ទេលផែង ឱ្យវាដាយនឹងព្រេចសម្លាប់, ដំរីសឹកនោះក៏បែរជាញ័រចំប្រប់ ពុំហ៊ានព្រេចជនទាំងនោះឡើយ ។ ព្រះមហាក្សត្រិយ៍ទ្រង់បានជ្រាបហេតុដ៏អស្ចារ្យចម្លែកនេះ, ព្រះអង្គក៏មានព្រះរាជបញ្ជាឱ្យហៅជនទាំងនោះចូលមកគាល់ ។ លុះទ្រង់ជ្រាបការពិតសព្វគ្រប់ហើយ ក៏ភ្ញាក់ព្រះសតិ មានព្រះរាជហឫទ័យជ្រះថ្លា

---

១- គាមភោជ ប្រែថា មន្ត្រីអ្នកបរិភោគនូវសួយអាករដែលមានក្នុងស្រុក លោកអ្នកបេះបាលីខ្លះប្រែស័ព្ទនេះថា ចៅហ្វាយស្រុក, ខ្លះប្រែថា មេស្រុក ។ ក្នុងសម័យបុរាណព្រេងនាយ គាមភោជនេះ ឥតមានបៀវត្សរ៍ទេ មានត្រឹមតែសួយអាករក្នុងស្រុកនោះឯងជាប្រយោជន៍បានមកខ្លួន តាមស្រុកធំស្រុកតូច ។

ចំពោះជនទាំង ៣៤ នាក់, ទ្រង់ព្រះរាជទានគាមភោជកព្រមទាំងប្រពន្ធកូនឱ្យជាទាសាទាសីនៃមឃមាណពនិងមិត្រទាំង ៣៣នាក់ ។ ដំរីសឹកនោះក៏ព្រះអង្គប្រទានឱ្យជាជំនិះនៃជនទាំងនោះដែរ.។ ស្រុកដែលគាម-ភោជកចិត្តបាបអាក្រក់កាន់កាប់មកនោះ ព្រះមហាក្សត្រិយ៍ក៏ប្រោសប្រ-ទានឱ្យជាស្រុកសួយនៃជនទាំង ៣៤នាក់ នោះផងទៀត ។

មឃមាណពនិងមិត្រទាំង៣៣នាក់ កាលបើបានឃើញផលបុណ្យជាទិដ្ឋធម្មវេទនីយឱ្យផលដ៏អស្ចារ្យ ឃើញជាក់ស្តែងទាន់ភ្នែកដូច្នេះ ក៏និយាយគ្នាថា **ឥទានិ អម្ហេហិ អតិរេកតរំ ភាគញ្ច** ឥឡូវ, យើងត្រូវតែធ្វើបុណ្យឱ្យច្រើនក្រៃលែងជាងពីមុនទៅទៀត ។ ក៏មូលមតិគ្នាថា យើងត្រូវសង់សាលាសំណាក់មួយ ។ ក៏បានហៅជាងឈើឱ្យមកផ្តើមសង់សាលាសំណាក់ លើទីដីដែលគួរសង់ ត្រង់ប្រជុំផ្លូវបែកជាបួន, ប៉ុន្តែមិនត្រូវឱ្យស្ត្រីមានសិទ្ធិចូលធ្វើសាលានេះជាមួយនឹងយើងផងទេ (ព្រោះមិនចង់កើតជួបនឹងស្ត្រីទៅជាតិមុខទៀត) ។

មឃមាណពមានប្រពន្ធ៤នាក់គឺ នាង **សុធម្មា១** នាង **សុនន្ទា១** នាង **សុចិត្តា** ១ នាង **សុជាតា ១** ។ បណ្តាប្រពន្ធទាំង៤ នាក់នោះ, នាង **សុធម្មា** មានគំនិតឈ្លាសវៃគិតថា អញនឹងធ្វើបុណ្យរួបរួមចូលជា-មួយនឹងប្តីឱ្យត្រាតែបាន, ក៏បានលបនិយាយត្រូវមាត់ត្រូវពាក្យគ្នាជាមួយ-នឹងជាងឈើ, បានឱ្យជាងឈើលបធ្វើ**ហោជាង**ឱ្យត្រូវនឹងខ្នាតសាលា

នោះ, បានឱ្យឆ្លាក់អក្សរនៅហោជាងថា **សាលាសុធម្មា** ។ លុះដល់ថ្ងៃត្រូវលើកហោជាង, ស្រាប់តែជាងឈើធ្វើអាការដូចជាភ្ញាក់ថាឱ, វរតែម្ដង! ខ្ញុំពុំបានគិតធ្វើហោជាងទុកជាមុន, ឥឡូវបើនឹងធ្វើឱ្យបានទាន់ការប្រញាប់ក៏ពុំកើត, ដ្បិតនឹងយកឈើស្រស់ៗមកធ្វើពុំកើតទេ, បើអ៊ីចឹង តើធ្វើម៉េចទៅហ៏! ខ្ញុំបានឃើញហោជាងគេធ្វើហើយស្រេច ទុកនៅផ្ទះគេឯណោះ, ប្រហែលជាត្រូវខ្នាតនឹងសាលាយើងនេះ, បើយើងទិញគេ ប្រហែលជាគេលក់ទេដឹង ? ។ ជនទាំង៣២នាក់ ក៏យល់ព្រមហើយនាំគ្នាទៅទិញ ដោយឱ្យថ្ងៃដល់មួយពាន់កហាបណៈ ។ នាង **សុធម្មា** មិនព្រមលក់ឱ្យ, ព្រមតែចូលបុណ្យជាមួយផង ។ មឃមាណពនិងមិត្រទាំង ៣៣ នាក់ មិនព្រមឱ្យស្ត្រីធ្វើបុណ្យជាមួយ ។ ជាងឈើប្រើឧបាយនិយាយពន្យល់ថា ក្រៅពីឋានព្រហ្ម គ្មានឋានណាមួយឥតស្ត្រីទេ, យើងប្រញាប់ចង់ឱ្យសាលាយើងហើយស្រេច, ណ្ហើយ, យកហោជាងហ្នឹងទៅ! ។ ជនទាំង ៣២ នាក់ទាល់គំនិត ក៏ព្រមយកហោជាងរបស់នាងសុធម្មានោះមកលើកដាក់ជាហោជាងសាលាសំណាក់នោះ ដោយឥតរង្កៀសអ្វីឡើយ ។ ជនទាំងពួងដែលមកកាន់ទីនេះ អានអក្សរជាឈ្មោះសាលានៅហោជាងថា **សាលាសុធម្មា**ៗ គេស្គាល់រាល់គ្នាថា **សាលាសុធម្មា,** ឯជនទាំង ៣២ នាក់ក៏ឥតមានអាការអាក់អន់ស្រពន់ចិត្តអ្វីព្រោះឈ្មោះសាលានេះទេ ។

មឃមាណពបានដាំដើម **កោវិឡារព្រឹក្ស** ដើមរលួសផ្កុងមួយដើម ឱ្យជាម្លប់ក្បែរសាលានោះ; បានយក **ថ្មដា** មួយផ្ទាំងធំមកដាក់ក្រោមដើមរលួសផ្កុង សម្រាប់ឱ្យគេអង្គុយសម្រាកក្នុងម្លប់ឈើនេះ ។

នាង **សុនន្ទា** ក៏មានយោបល់ឈ្លាសវៃណាស់ដែរ, បានចាត់ការឱ្យជីក **ស្រះបោក្ខរណី** គឺស្រះឈូកមួយនៅទីមិនឆ្ងាយប៉ុន្មានពីសាលាសុធម្មានោះ, ស្រះនេះមានទឹកដក់នៅជានិច្ច ជាទីពេញចិត្តនៃនាងនិងជនទាំងពួង , ជាសាធារណប្រយោជន៍ពល់ទិវារាត្រី ។

នាង **សុចិត្តា** ក៏ជាស្ត្រីឈ្លាសវៃណាស់ដែរ, បានចាត់ការឱ្យដាំ **សួន** នៅទីមិនឆ្ងាយពីសាលាសុធម្មានោះប៉ុន្មាន, សួនច្បារនោះមានសុទ្ធសឹងតែឈើមានផ្កាមានផ្លែ ជាទីពេញចិត្តនៃខ្លួននិងជនទាំងពួង ។ ជនទាំងពួងដែលចូលមកកាន់ទីនេះ ក៏តែងតែមានចិត្តរីករាយសប្បាយក្សេមក្សាន្ត បានកែអផ្សុកធូរចិត្តគំនិតទាំងអស់គ្នា ។

រីឯនាង **សុជាតា** ប្រពន្ធទី៤ ត្រូវជាប្អូនជីដូនមួយខាងម្តាយនៃមឃមាណពផង បានមកជាប្រពន្ធនៃមាណពនេះផង ។ នាងនេះជាស្ត្រីមិនឈ្លាសវៃ, មិនអាចញ៉ាំងចិត្តឱ្យជ្រះថ្លាចំពោះការកុសល, នាងនេះយល់ខុសទាំងស្រុងថា អញជាប្អូនជីដូនមួយនៃមឃៈផង ជាប្រពន្ធគាត់ទៀតផង, ការអ្វីដែលប្តីអញគាត់បានធ្វើ ក៏ជាការរបស់អញដែរ, ប្តីអញធ្វើបុណ្យ អញក៏ត្រូវតែបានបុណ្យដូចជាគាត់ដែរ ព្រោះអញនិង

ប្ដីអញមានអំពើកិច្ចការរួមគ្នាតែមួយ ។ នាងសុជាតាគិតខុសយ៉ាងនេះ ក៏ឥតបើអើពើ ឥតមានសទ្ធាជ្រះថ្លា ឥតមានការលៃលកធ្វើបុណ្យអ្វីដូចជានាងទាំង ៣ នាក់ នោះសោះឡើយ, គិតមួយតែពីខាងតាក់តែងស្អិតស្អាងខ្លួនឱ្យតែគាប់ចិត្តប្ដីប៉ុណ្ណោះ ។ នាងនេះ ជាស្ត្រីមោឃាឃែតចាកកុសលកម្ម ព្រោះខ្លួនជាស្ត្រីល្ងង់វាតឃ្លាតចាកមនុស្សធម៌ ក្លាយទៅជាស្ត្រីអភ័ព្វ ។

លុះចំណេរកាលមកខាងមុខ, ជនទាំងនោះក៏រំលាងខន្ធអស់ជីពជន្មតាមលំដាប់កាលរៀងខ្លួន, សុទ្ធសឹងតែបានទៅកើតឯឋានត្រ័យត្រិង្សសួគ៌[១] ទាំងអស់គ្នា ។

មឃមាណព បានទៅកើតជា ព្រះឥន្ទ នៅឋានត្រ័យត្រិង្សសួគ៌ជាស្ដេចទេពតា មាននាមពិសេសមួយយ៉ាងថា **មឃវា** ឬ **មឃទេវរាជ** តាមនាមដើមកាលនៅជាមនុស្សឈ្មោះ**មឃៈ** ។

អានិសង្សនៃសាលាសំណាក់ បានកើតជាប្រាសាទទិព្វឈ្មោះ **វេជ-យ័ន្ត** ជាវិមានសម្រាប់ព្រះឥន្ទ ។

អានិសង្សនៃការដាំកោវិឡាព្រឹក្ស គឺដើមរលួសផ្ដុងជាម្ចប់ឱ្យគេជ្រកនោះ បានកើតជាដើមឈើទិព្វមួយដើមហៅថា **បារិច្ឆត្តកព្រឹក្ស** ឬហៅថា **បារិជាតកព្រឹក្ស** ក៏បាន នៅឋានត្រ័យត្រិង្ស ។

១- បណ្ដាឋានសួគ៌ទាំង ៦ ជាន់, ត្រៃត្រិង្ស ជាឋានសួគ៌ជាន់ទី ២ ។

អានិសង្សនៃ **ថ្មដា** មួយផ្ទាំងធំ ដែលមឃមាណពបានដាក់តម្កល់ក្រោមដើមរលួសផ្អុង សម្រាប់ឱ្យគេអង្គុយកំសាន្តនោះ បានកើតជាថ្មទិព្វឈ្មោះ **បណ្ឌុកម្ពលសិលា** ជាថ្មមានសម្បុរដូចជាសំពត់កម្ពលក្រហមប្រតិស្ឋាននៅក្រោមដើមបារិច្ឆត្តកព្រឹក្ស នៅឋានត្រ័យត្រិង្ស ជាអាសនៈ, សម្រាប់ព្រះឥន្ទគង់កំសាន្តមួយដង់មួយកាល ឬគង់រំពឹងមើលហេតុការណ៍អ្វីមួយដែលប្លែកគួរឱ្យព្រងើយកន្តើយពុំកើត ។

ជនទាំង៣៣នាក់ជាមិត្រនៃមឃមាណព លុះអស់ជីវិត ក៏បានទៅកើតជាទេវបុត្រឋានត្រ័យត្រិង្សសួគ៌ សុទ្ធសឹងតែមានប្រាសាទវិមានទិព្វទីទៃៗ រៀងខ្លួន ។ ដោយហេតុនេះ បានជាឋានសួគ៌នោះ, ដែលពីដើម ជាឋានរបស់ពួកអសុរមាន **វេបចិត្តិអសុរិន្ទ** ជាប្រមុខ, ក៏ត្រឡប់បានមកជាឋានរបស់ព្រះឥន្ទនិងពួកទេវតាថ្មីនោះទៅវិញ, មានឈ្មោះថាឋាន**ត្រ័យត្រិង្ស** ឬ **តាវត្តិង្ស** ពីព្រោះមុនដំបូងទេវតាពួកនេះមានគ្នា ៣៣ រូប ដោយមានព្រះឥន្ទជាស្តេចគ្រប់គ្រង ។ ព្រះឥន្ទថែមទាំងមានអំណាចត្រួតត្រាលើពួកលោកបាលទេវរាជទាំង ៤ នៅឋាន**ចាតុម្មហារាជិកាសួគ៌** ផងទៀត ។ ឋានត្រ័យត្រិង្ស នៅលើផ្ទៃកំពូល

នៃ **ភ្នំសុមេរុ** ។ ឯឋាន **ចាតុម្មហារាជិកា** នៅលើកំពូល **ភ្នំបរិភណ្ឌ**[១] ក្នុងទិសធំទាំង ៤ ជិត **ភ្នំសុមេរុ** ។

ជាងឈើ ទៅកើតជា **វិស្សកម្មទេវបុត្ត** ក្នុងត្រ័យត្រិង្សសួគ៌ដែរ ។

**ដំរីសឹក** ដែលព្រះរាជាមគធរដ្ឋទ្រង់ប្រោសប្រទានឱ្យជាជំនិះនៃមឃមាណពនិងមិត្រទាំង ៣៣នាក់នោះ លុះអស់ជីវិត ក៏បានទៅកើតជា **ឯរាវណទេវបុត្ត** នៅឋានត្រ័យត្រិង្ស ។ ក្នុងឋានសួគ៌មិនមានសត្វតិរច្ឆានមែនទែនទេ ប៉ុន្តែ កាលបើព្រះឥន្ទនិងទេវបុត្តជាមិត្រទាំង ៣៣ រូបនោះត្រូវការឱ្យមានដំរីទិព្វជាជំនិះមួយដងមួយកាល, **ឯរាវណទេវបុត្ត** ក៏និម្មិតឱ្យខ្លួនក្លាយទៅជាដំរីទិព្វមួយធំមានក្បាលចំនួន ៣៤, ក្បាលមួយចំកណ្តាលជាជំនិះព្រះឥន្ទ និងក្បាល ៣៣ ឯទៀត ជាជំនិះទេវបុត្រទាំង ៣៣ រូប ។ ដំរីនិម្មិតនោះឈ្មោះថា **ឯរាវ័ណ**, កាលបើបានបំពេញកិច្ចរបស់ខ្លួនរួចហើយ ក៏ក្លាយខ្លួនទៅជាទេវបុត្រដូចដើមវិញដដែល, ឯប្រាសាទវិមានរបស់ខ្លួនមានស្រេចស្រាប់ជាធម្មតា ។

នាង **សុធម្មា** បានទៅកើតជាស្ត្រីសួគ៌មានឈ្មោះថា **សុធម្មា** ដដែល, ជាជាយានៃព្រះឥន្ទ ។ អានិសង្សនៃ**ហោជាង** ដែលនាងបាន

---

១- ភ្នំបរិភណ្ឌនេះមាន៧ មានឈ្មោះថា យុគន្ធរ , នេមិន្ធរ ឥសធរ ឬ ឥសិធរ, ករវីក, សុទស្សនៈ វិនតក, អស្សកណ្ណ ហៅថា ភ្នំសត្តបរិភណ្ឌ ។ ភ្នំបរិភណ្ឌទាំង ៧ នេះ នៅព័ទ្ធជុំវិញភ្នំសុមេរុ។ មានឈ្មោះហៅបាន ៥ យ៉ាងគឺ សិមេរុ មេរុ, នេរុ, សិនេរុ, តិទិវាធរ ។ បណ្តាឈ្មោះទាំង ៥ យ៉ាងនេះ តិទិវាធរ ជាឈ្មោះបញ្ជាក់ឱ្យឃើញថា ភ្នំទ្រទ្រង់នូវឋាន តិទិវៈ គឺឋានត្រ័យត្រិង្ស ដ្បិតឋានត្រ័យត្រិង្ស ឋិតនៅលើកំពូលភ្នំនេះ។

ចូលបុណ្យជាមួយនឹងមឃមាណពជាប្ដីនោះ បានកើតជាសាលាទិព្វមួយធំទូលំទូលាយ នៅឋានត្រ័យត្រិង្ស, សាលាទិព្វនេះឈ្មោះ **សុធម្មា-ទេវសភា** ជាសាលាទិព្វដែលទេវតាទាំងឡាយតែងមកប្រជុំគ្នា តាមពេលដែលត្រូវប្រជុំ មានថ្ងៃ ៨ កើតនៃមនុស្សលោកជាដើម ។

នាង **សុនន្ទា** បានទៅកើតជាស្ត្រីសួគ៌ដែរ មានឈ្មោះថា **សុនន្ទា** ដដែល, ជាជាយានៃព្រះឥន្ទ ។ អានិសង្សនៃ**ស្រះបោក្ខរណី**គឺស្រះឈូករបស់នាងនោះ បានកើតជាស្រះបោក្ខរណីទិព្វមួយធំទូលាយ នៅឋានត្រ័យត្រិង្ស មានឈ្មោះថា **ស្រះនន្ទា** ជាទីកំសាន្តសប្បាយនៃពួកទេវតា ។ នាង **សុចិត្តា** បានទៅកើតជាស្ត្រីសួគ៌ជាជាយានៃព្រះឥន្ទដែរ មាននាមថា **សុចិត្តា** ដូចដើមដដែល ។ អានិសង្សនៃសួនរបស់នាងនោះ បានកើតសួនទិព្វធំមួយ នៅឋានត្រ័យត្រិង្ស មានឈ្មោះថាសួន **ចិត្តលតាវ័ន** ជាទីកំសាន្តនៃទេវតាទាំងឡាយ ។ កាលបើទេពតាណាជិតនឹងច្យុត តែងតែមានបុព្វនិមិត្តទាំង ៥ ណាមួយកើតប្រាកដឡើង, ជួនកាលទេពតាឯទៀតគេបានដឹង គេតែងនាំទេពតាដែលជិតនឹងច្យុតនោះឱ្យទៅកំសាន្តនៅសួនទិព្វឈ្មោះ **ចិត្តលតាវ័ន** នេះ ដើម្បីបន្ធូរចិត្តកុំឱ្យតក់ស្លុត ។

**សុជាតា បន កាលំ កត្វា ឯកិស្សា គិរិកន្ទរាយ ពកសកុណិកា ហុត្វា និព្វត្តិ** ប្លែកពីគេតែនាង **សុជាតា** ដែល

ជាស្ត្រីល្ងង់យល់ខុស, លុះធ្វើមរណកាលស្លាប់ ទៅកើតជា **កុកញី**នៅទីជិតញកភ្នំមួយ, បេះតែសព្ទារភ្ញើកចុះភ្ញើកឡើងរកមច្ឆជាតិជាចំណីអាហារ តាមធម្មតារបស់សត្វកុក ។

ព្រះឥន្ទ **មឃទេវរាជ** រំពឹងឃើញថា នាងសុធម្មា, សុនន្ទា, សុចិត្តា, បានមកកើតនាឋានត្រ័យត្រិង្សជាមួយនឹងអញដែរហើយ, ចុះ**នាងសុជាតា** តើស្លាប់ទៅកើតនៅទីណា? ទ្រង់ជ្រាបច្បាស់ដោយ**ញាណទិព្វថា** ឱ ! សុជាតាអើយ ! ហេតុតែវាល្ងង់ វាយល់ខុស, វាឥតមានសទ្ធាជ្រះថ្លា ឥតបានធ្វើបុណ្យអ្វីបន្តិចបន្តួចសោះ ឥឡូវវាទៅកើតជាសត្វតិរច្ឆាន; ឱ, គួរអាណិតវាណាស់; ឥឡូវ អញគួរតែទៅណែនាំវាឱ្យធ្វើបុណ្យ ហើយនឹងនាំយកវាមកក្នុងឋានត្រ័យត្រិង្សនេះ ឱ្យវាបានជាភរិយាអញដូចពីដើមតទៅទៀត ។

លំដាប់នោះ, ព្រះឥន្ទក៏ចុះមកកាន់ឋានមនុស្ស, បាននិម្មិតព្រះអង្គជាសត្វកុក, បាននាំកុកញីនោះទៅឋានត្រ័យត្រិង្ស, រួចហើយនាំយកមកកាន់កន្លែងដើមវិញ, បានពន្យល់ណែនាំឱ្យកាន់សីល ៥ ខ្ទាប់ ។ តពីនោះមក, ព្រះឥន្ទបានចុះមកពិសោធ ៣ ដង, ដោយនិម្មិតធ្វើជាត្រីងាប់, លុះកុកញីឃើញត្រីងាប់ ក៏ចាប់ដោយចំពុះបម្រុងនឹងលេប, ត្រីងាប់នោះក៏កម្រើកចុងកន្ទុយខ្វើកៗ ឱ្យដឹងថាជាត្រីរស់ទេ, កុកញីក៏លេងហ៊ានស៊ីទៅវិញ ។ កុកញីអត់អាហារដោយរកត្រី

ផាប់ស៊ីពុំបាន ព្រោះខ្លាចដាច់សីល ក៏ចេះតែស្គមទៅៗ, ពុំយូរថ្ងៃប៉ុន្មាន ក៏ផាប់ទៅ ទៅកើតជាកូនស្រីនៃស្មូនឆ្នាំងនៅក្រុង ពារាណសី ដែនកាសី ។ ព្រះឥន្ទក៏និម្មិតព្រះអង្គជាឈ្មួញម្នាក់បររទេះពាយនាយលក់ផ្លែល្ពៅ ដែលសុទ្ធតែជុំមាសសោះទេ, បានឱ្យផ្លែល្ពៅទាំងអស់នោះទៅនាង ឱ្យជាស្ត្រីមានទ្រព្យសម្បត្តិបរិបូណ៌, បានណែនាំឱ្យធីតានោះកាន់សីល ៥ រឹតតែខ្ជាប់ខ្ជួនឡើងទៀត ។ លុះធីតានៃស្មូនឆ្នាំងអស់ជីពជន្មក៏បានទៅកើតជាបុត្រីនៃ **វេបចិត្តិអសុរិន្ទ** ជាវេរិបុគ្គលនៃព្រះឥន្ទ ព្រោះអសុរនេះជាសត្រូវនឹងព្រះឥន្ទ តាំងពីកាលដែលបរាជ័យចាញ់អំណាចព្រះឥន្ទ ហើយបានឋានត្រ័យត្រិង្សទៅព្រះឥន្ទនិងទេពតាជាមិត្ររបស់ព្រះឥន្ទ, ក៏ជាប់មានគំនុំរៀងមក, បុត្រីនៃអសុរនេះ មាននាមថា **សុជាតា** ដូចនាមដើម ជាអសុរកញ្ញា ហៅថា **សុជាតា-អសុរកញ្ញា** ។ ដោយអំណាចផលានិសង្សនៃ **សីល ៥** ដែលនាងនេះបានរក្សាហ្មត់ចត់តាំងពីនៅជាកុកញីរៀងមក, អសុរកញ្ញានេះមានរូបឆោមលោមពណ៌ល្អស្អាតឥតខ្ចោះ ។ នាងនេះចេះតែប្រកែកពុំព្រមទទួលយកបុរសអសុរណាមួយ ជាគូស្រករសោះ, ទើបវេបចិត្តិអសុរិន្ទជាបិតា អនុញ្ញាតឱ្យជ្រើសរើសគូស្រករតាមចិត្តខ្លួនចុះ ។ នៅពេលដែលពួកអសុរកំលោះៗ កំពុងជុំកុះករដើម្បីបង្ហាញខ្លួនឱ្យនាងនេះជ្រើសរើសគូស្រករ, ព្រះឥន្ទបានជ្រាបការណ៍នេះក៏ស្ដេចយាងមកនិម្មិតព្រះអង្គជាអសុរចាស់ម្នាក់ ឈរត្រង់ទីបំផុតនៃពួក

អសុរទាំងនោះ ។ ហេតុតែនាងធ្លាប់ជាភរិយា កាលនៅជាមយមាណពនោះ នាងក្រឡេកឃើញអសុរចាស់ក៏ស្រឡាញ់ ហើយបោះភួងផ្កាទៅឱ្យតានោះ តាអសុរចាស់ក៏ចាប់ភួងផ្កា ហើយយកនាងអសុរកញ្ញានោះហោះទៅ ឋានត្រ័យត្រិង្ស ទៅនៅជាសុខក្នុងទីនោះរហូតមកសព្វថ្ងៃ នេះហើយជា អានិសង្សនៃការសាងផ្លូវថ្នល់ ឱ្យបានសុខស្រួលដល់សាធារណជន តែង បានសេចក្ដីសុខដល់ខ្លួនវិញ ដែលត្រូវតាមគន្ធងនៃការពិតថា:

**សុខស្ស ធាតា មេធាវី សុខំ សោ អធិគច្ឆតិ**

ជនដ៏មានប្រាជ្ញាណា បានឱ្យសេចក្ដីសុខដល់អ្នកដទៃ ជននោះឯងរមែង បានជួបប្រទះនឹងសេចក្ដីសុខ ៕

សង្ខេបតែប៉ុណ្ណោះ